ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## វឌ្ឍនភាពនៃការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គាវើលដ៍ នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០២២

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារណជន ឱ្យបានជ្រាបថា ក្រសួងបានបន្តសម្របសម្រួលវិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គាវើលដ៍ ស្របតាមតួនាទីដែលមានចែងក្នុងច្បាប់ជាធរមាន ក៏ដូចជាស្របតាមស្មារតីចង់បានរបស់តំណាងភាគីកម្មករនិយោជិតដែលចង់ជួបចរចាជាមួយក្រុមហ៊ុនផ្ទាល់។ នៅរសៀលថ្ងៃទី៦ ខែមេសា ឆ្នាំ២០២២ នេះ ក្រសួងបានបន្តអញ្ជើញគូភាគីវិវាទមកជួបប្រជុំដោះស្រាយជាលើកទី៧ ក្រោមអធិបតីភាពរបស់ឯកឧត្តម ទេស រុក្ខាផល អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ក.ប. ដោយមានតំណាងភាគីកម្មករនិយោជិត រួមមាន លោកស្រី ឈឹម ស៊ីថរ, លោកស្រី ឈឹម សុខន, លោកស្រី រី សុវណ្ណឌី, លោកស្រី សុន ស្រីពេជ្រ, លោកស្រី ហៃ សុភាព និងតំណាងភាគីនិយោជក រួមមានលោក **Hein Dames**, លោកស្រី ឌី សីហា និងលោកស្រី រស់ ប៊ុនឡេង ដោយភាគីទាំងពីរបានលើកឡើងនូវមតិយោបល់ដូចខាងក្រោម៖

**មតិរបស់សហជីព និងតំណាងភាគីកម្មករនិយោជិត៖**

១. សង្ឃឹមថានឹងមានពន្លឺនៃដំណោះស្រាយករណីវិវាទនេះ ហើយនៅតែរក្សាជំហរនៃការទាមទារសុំចូលធ្វើការងារវិញ។

២. បុគ្គលិកដែលទាមទារចូលធ្វើការងារវិញបានថយចុះពី ៣០០នាក់ មកនៅត្រឹមជាង ២០០នាក់វិញ ហើយក្រុមហ៊ុន ណាហ្គាវើលដ៍ តែងតែផ្តល់ការងារឱ្យប្រជាពលរដ្ឋខ្មែរឱ្យមានការងារធ្វើ។ ដូចនេះ ស្នើសុំឱ្យក្រុមហ៊ុនផ្តល់ការងារធ្វើជូនបុគ្គលិកដែលមានជំនាញស្រាប់ និងមានបទពិសោធន៍ការងារយូរឆ្នាំ មិនចាំបាច់បណ្តុះបណ្តាលឡើងវិញ ស្របពេលដែលក្រុមហ៊ុនត្រៀមដំណើរការអគារថ្មីដែរ។ សហជីពយល់ឃើញថា ការស្នើសុំដោះដូរនេះ មិនធ្វើឱ្យក្រុមហ៊ុនមានការខាតបង់អ្វីដែរ។ សមាសភាពបុគ្គលិកដែលស្នើចូលធ្វើការងារនេះ គឺជាថ្នាក់ដឹកនាំសហជីព ជាសមាជិក និងជាសកម្មជនសហជីពទាំងអស់។

៣. ស្នើសុំឱ្យអធិការការងារបកស្រាយនូវការបញ្ឈប់ពីការងាររួម ស្របតាមមាត្រា៩៥ នៃច្បាប់ស្តីពីការងារ។

៤. ស្នើសុំឱ្យខាងក្រសួងលើកយកច្បាប់ដែលពាក់ព័ន្ធនឹងវិវាទ មកថ្លឹងថ្លែងផ្តល់យុត្តិធម៌ជូនភាគីរវាងថៅកែ និងកម្មករ។ ក្រុមហ៊ុនបានយកហេតុផលវិបត្តិជំងឺកូវីដ-១៩ យកមកបញ្ឈប់ជនរងគ្រោះ ដោយសារជំងឺកូវីដ-១៩ ដែលពួកយើងជាជនរងគ្រោះនេះ យល់ឃើញវាជាហេតុផលដែលអមនុស្សធម៌បំផុត ពីព្រោះក្រុមហ៊ុននៅតែចំណេញ គ្រាន់តែចំណេញតិចជាងមុន វាធ្វើឱ្យពួកយើងដែលជាជនរងគ្រោះមានការឈឺចាប់ខ្លាំងបំផុត។ ក្នុងនាមជាតំណាងកម្មករនិយោជិតស្នើសុំទៅក្រសួងពាក់ព័ន្ធទាំងអស់ សូមផ្តល់យុត្តិធម៌និងកុំធ្វើឱ្យពួកយើងឈឺចាប់ម្តងហើយម្តងទៀត។

៥. សំណូមពរឱ្យស្ថាប័នពាក់ព័ន្ធលើកលែងបទចោទចំពោះតំណាងកម្មករនិយោជិតទាំងអស់។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

មតិរបស់តំណាងក្រុមហ៊ុន ណាហ្គាវើលដ៍៖

១. ថ្លែងអំណរគុណដល់ប្រធានអង្គប្រជុំ មន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ត្រីរដ្ឋបាលរាជធានីភ្នំពេញ និងសមាជិកអង្គប្រជុំទាំងអស់។

២. សម្រាប់កិច្ចប្រជុំថ្ងៃនេះ ក្រុមហ៊ុនសូមធ្វើការឆ្លើយតបជាផ្លូវការទៅនឹងលិខិតរបស់សហជីពដែលដាក់ជូនមកក្រុមហ៊ុន កាលពីថ្ងៃទី២៣ ខែមីនា កន្លងមក។ ក្រុមហ៊ុននៅរក្សាជំហរដដែលដូចដែលបានបញ្ជាក់នៅក្នុងកិច្ចប្រជុំកន្លងមក។ ក្រុមហ៊ុនសូមអានខ្លឹមសារនៃលិខិតឆ្លើយតបជាផ្លូវការរបស់ក្រុមហ៊ុនជូនចំពោះសហជីពដែលស្នើសុំឱ្យក្រុមហ៊ុនទទួលយកកម្មករនិយោជិតដែលនៅសល់ចំនួន ២០០នាក់ ចូលធ្វើការងារវិញ។

៣. ក្រុមហ៊ុនដាក់ជូនលិខិតឆ្លើយតបទៅភាគីសហជីព និងចម្លងជូនមក អគ្គលេខាធិការដ្ឋានគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា។

៤. ក្រុមហ៊ុននៅតែរក្សាជំហរដោះស្រាយវិវាទដោយមេត្រីភាពជាមួយសហជីព ហើយក្រុមហ៊ុនស្នើសុំឱ្យសហជីពគួរលើកឡើងនូវដំណោះស្រាយមួយដែលអាចទៅរួចជាងសំណើបច្ចុប្បន្នរបស់ខ្លួននេះ ដើម្បីឱ្យក្រុមហ៊ុនយកទៅពិចារណា និងសិក្សាថាតើក្រុមហ៊ុនអាចទទួលយកបាន ឬយ៉ាងណា។

ក្រៅពីការឆ្លើយតបរបស់តំណាងភាគីនិយោជក អធិការការងារបានពន្យល់អំពីគោលការណ៍ និងខ្លឹមសារមាត្រា៩៥ នៃច្បាប់ស្តីពីការងារ ជូនភាគីទាំងពីរជាថ្មីម្តងទៀតផងដែរ។

ក្រោយពីការពិភាក្សាគ្នាយ៉ាងផុសផុល ភាគីទាំងពីរបានឯកភាព ដូចខាងក្រោម៖

១. ភាគីទាំងពីរ នៅមិនទាន់ឈានដល់ចំណុចព្រមព្រៀងគ្នានៅឡើយទេ។

២. កំណត់កាលបរិច្ឆេទប្រជុំបន្ទាប់ នៅថ្ងៃព្រហស្បតិ៍ ទី២១ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ១៤:៣០នាទី ដើម្បីឱ្យភាគីទាំងពីរមានឱកាសពិចារណាឡើងវិញ អំពីលទ្ធភាពនៃការសម្បទានគ្នាទៅវិញទៅមកដែលអាចឈានទៅបញ្ចប់វិវាទនេះ។

ឆ្លៀតក្នុងឱកាសនេះ ក្រសួងសូមបញ្ជាក់ផងដែរថា បើទោះបីជាមិនទាន់មានការឯកភាពគ្នា ក៏ក្រសួងនឹងបន្តខិតខំធ្វើការសម្របសម្រួល និងកំណត់កាលបរិច្ឆេទប្រជុំបន្តបន្ទាប់ទៀត ស្របតាមតួនាទីដែលកំណត់ដោយច្បាប់ ក៏ដូចជាការទាមទាររបស់គូភាគី។

ជាថ្មីម្តងទៀត ក្រសួងស្នើឱ្យភាគីទាំងពីរមានការយោគយល់គ្នាខ្ពស់ក្នុងការចូលរួមដោះស្រាយបញ្ចប់វិវាទការងារនេះ, បន្តសហការជិតស្និទ្ធជាមួយអាជ្ញាធរមានសមត្ថកិច្ច និងភាគីពាក់ព័ន្ធដោយសន្តិវិធី, និងថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។ យោងតាមនីតិវិធីច្បាប់ ប្រសិនបើវិវាទការងារនេះមិនអាចស្វែងរកដំណោះស្រាយបានដោយការផ្សះផ្សា នីតិវិធីបន្ទាប់គឺអាចបញ្ជូនទៅតុលាការ ដើម្បីរកដំណោះស្រាយចុងក្រោយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជ្រាបតាមការគួរ។

ថ្ងៃពុធ ៥កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២២